ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តតាកែវ

-សំណុំរឿងព្រហ្មទណ្ឌលេខៈ ៦៥៨
ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១
-សាលក្រមព្រហ្មទណ្ឌលេខៈ ៦០ "ឆ"
ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២

# សាលក្រម

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តតាកែវ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តតាកែវ នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ៩ និង ៣០នាទីព្រឹក ដោយមានសមាសភាពចូលរួមដូចតទៅ:

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រម នៃសាលាដំបូងខេត្តតាកែវ

**ចៅក្រមប្រឹក្សា**

លោក [redacted]ក្រម នៃសាលាដំបូងខេត្តតាកែវ

លោក [redacted] ចៅក្រម នៃសាលាដំបូងខេត្តតាកែវ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខៈ ៦៥៨ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលមានជនជាប់ចោទៈ

១-ឈ្មោះ [redacted] អ៊ៅ ហៅ វ៉ៃ ភេទប្រុស អាយុ២៤ឆ្នាំ (កើតឆ្នាំ១៩៩៨) ជនជាតិខ្មែរ មុខរបរជាងពិដាន មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តតាកែវ ឪពុកឈ្មោះ [redacted] ងួន (រស់) ម្តាយឈ្មោះ [redacted] សំអឿន (រស់) នៅលីវ ជានីតិជន កម្រិតវប្បធម៌រៀនថ្នាក់ទី០៣ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការៈ គ្មាន។ (ឃុំខ្លួនថ្ងៃទី១២-១១-២០២១)

២-ឈ្មោះ [redacted] ណាន ភេទប្រុស អាយុ៣២ឆ្នាំ (កើតឆ្នាំ១៩៩២) ជនជាតិខ្មែរ មុខរបរជាងពិដាន មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តតាកែវ ឪពុកឈ្មោះ [redacted] យោន (រស់) ម្តាយឈ្មោះ [redacted] សារី (រស់) មានប្រពន្ធឈ្មោះ [redacted] សុលីដា (រស់) មាន



Scanned with CamScanner

កូន ០២នាក់ ជានីតិជន កម្រិតវប្បធម៌រៀនថ្នាក់ទី០៧ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការៈ គ្មាន។ (ឃុំខ្លួនថ្ងៃទី១២-១១-២០២១)

ជាប់ចោទពីបទៈ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិត្រពាំងគៀប ឃុំត្រពាំងក្រសាំង ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-បានឃើញ របាយការណ៍សរុបលេខៈ ៣៦/២០២១ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ របស់កងរាជអាវុធហត្ថខេត្តតាកែវ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ១៤៧ ដ.ស.ព/២២ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តតាកែវ។

-បានឃើញ ដីកាដំណោះស្រាយលេខៈ ១៥៦ (ច) /២០២២ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តតាកែវ។

-បានឃើញ ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខៈ ១៩៨ ដចត/២២ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តតាកែវ។

-បានឃើញឯកសារផ្សេងៗក្នុងសំណុំរឿងព្រហ្មទណ្ឌខាងលើ។

## អង្គហេតុដែលប្តឹងមកតុលាការមានដូចតទៅៈ

កាលពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ១៥ និង ៣០នាទី មន្ត្រីនគរបាលយុត្តិធម៌ការិយាល័យប្រឆាំងគ្រឿងញៀននៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តតាកែវ បានចុះបង្ក្រាបករណីជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ស្ថិតនៅភូមិត្រពាំងគៀប ឃុំត្រពាំងក្រសាំង ស្រុកបាទី ខេត្តតាកែវ ដោយធ្វើការឃាត់ខ្លួនជនត្រូវចោទឈ្មោះ [redacted] ម៉ៅ ហៅ វ៉ៃ ភេទប្រុស អាយុ២៤ឆ្នាំ និងឈ្មោះ [redacted]ណាន ភេទប្រុស អាយុ៣០ឆ្នាំ ព្រមទាំងដកហូតបានថ្នាំញៀនប្រភេទមេតំហ្វេតាមីន (ICE) ចំនួន ០១កញ្ចប់ធំទម្ងន់ ៤១,៤៨ក្រាម (ថ្លឹងទាំងសំបក), ជញ្ជីងថ្លឹងថ្នាំញៀនចំនួន ០១គ្រឿង, សម្ភារៈប្រើប្រាស់ថ្នាំញៀន និងថង់វេចខ្ចប់គ្រឿងញៀនមួយចំនួន។ ក្រោយកើតហេតុសមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនមកសាលាដំបូងខេត្តតាកែវដើម្បីចាត់ការតាមនីតិវិធី។ តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] ណាន បានបញ្ជាក់ថាថ្នាំញៀនដែលខ្លួនលក់ឱ្យទៅឈ្មោះ [redacted] ម៉ៅ ហៅ វ៉ៃ គឺខ្លួនទិញមកពីឈ្មោះ ពណ៌ ភេទប្រុស អាយុប្រហែល៣០ឆ្នាំ រស់នៅចំណុចម្តុំក្លឹបកំសាន្តរ៉ុក សង្កាត់បឹងត្របែក រាជធានីភ្នំពេញ។

## នាពេលសវនាការ

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ហៅ វ៉ៃ បានឆ្លើយថាៈ ខ្ញុំបាទពុំបានប្រព្រឹត្តអំពើខាងលើដូចការចោទប្រកាន់នោះទេ។ ដោយនៅថ្ងៃកើតហេតុខ្ញុំបាទគ្រាន់តែបានប្រើប្រាស់ថ្នាំញៀនតែប៉ុណ្ណោះ



Scanned with CamScanner

ហើយចំណែកឯថ្នាំញៀនដែលសមត្ថកិច្ចបានដកហូតពីខ្ញុំបាទនោះ គឺឈ្មោះ [redacted] ណាន បានយកមកផ្ញើទុកនៅនឹងខ្ញុំបាទតែប៉ុណ្ណោះ ហើយនៅពេលសមត្ថកិច្ចឃាត់ខ្លួននោះ គឺបានដកហូតសម្ភារៈ និងជញ្ជីងចំនួនមួយគ្រឿង និងថ្នាំញៀនដែលឈ្មោះ [redacted] ណាន បានផ្ញើនៅនឹងខ្ញុំបាទទុកយកឱ្យគេបន្តតែប៉ុណ្ណោះ ដោយអ្នកដែលត្រូវមកយកថ្នាំញៀនពីខ្ញុំបាទ គឺមកយកចុះ ដោយខ្ញុំបាទមិនដែលបានវេចលក់ដោយផ្ទាល់នោះទេ ដោយគ្រាន់តែជាអ្នកទទួលថ្នាំពីឈ្មោះ [redacted] ណាន ដើម្បីទុកឱ្យគេតែប៉ុណ្ណោះ ហើយខ្ញុំបាទគ្រាន់តែទទួលបានថ្នាំញៀនយកមកជក់បន្តិច និងបានជក់តែប៉ុណ្ណោះ។ ខ្ញុំបាទធ្លាប់យកថ្នាំញៀនពីឈ្មោះ [redacted] ណាន យកមកទុកបានចំនួន ០២លើកមកហើយ។ ហើយចំពោះថ្នាំញៀនដែលសមត្ថកិច្ចបានដកហូតបាននោះ គឺជាថ្នាំញៀនដែលឈ្មោះ [redacted] ណាន បានយកមកផ្ញើទុកនៅនឹងខ្ញុំបាទមុនមួយថ្ងៃដែលសមត្ថកិច្ចឃាត់ខ្លួននោះ។ ចំពោះថ្នាំញៀនដែលខ្ញុំបាទធ្លាប់បានប្រើប្រាស់កន្លងមក គឺខ្ញុំបាទទិញពីឈ្មោះ [redacted] ណាន ដោយទិញម្តងៗក្នុងតម្លៃ ២ម៉ឺនរៀលតែប៉ុណ្ណោះ។ នៅពេលសមត្ថកិច្ចឃាត់ខ្លួនខ្ញុំបាទ គឺមានថ្នាំញៀនចំនួន ០១កញ្ចប់, ឧបករណ៍ប្រើប្រាស់មួយចំនួន, ជញ្ជីងថ្លឹងថ្នាំញៀនចំនួន ០១, ថង់សម្រាប់វេចខ្ចប់ពីរទៅបី ក្រៅពីនេះពុំមាននោះទេ។ ចំពោះចម្លើយរបស់ខ្ញុំបាទដែលបានឆ្លើយកន្លងមក គឺជាចម្លើយរបស់ខ្ញុំបាទពិតមែន។ ចំពោះថ្នាំញៀនដែលឈ្មោះ [redacted] ណាន ផ្ញើទុកឱ្យខ្ញុំបាទដើម្បីឱ្យឈ្មោះ ប៊ិប, ឈ្មោះ ភា និងឈ្មោះ ភាស់ មកយកពីខ្ញុំបាទ។

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ណាន បានឆ្លើយថាៈ ខ្ញុំបាទពិតជាស្គាល់ឈ្មោះ [redacted] ម៉ៅ ហៅ វ៉ៃ ពិតមែន ដោយធ្លាប់បានប្រើប្រាស់ជាមួយគ្នាផងដែរ។ ហើយខ្ញុំបាទក៏មិនដែលធ្លាប់បានលក់ថ្នាំញៀនឱ្យទៅឈ្មោះ [redacted] ម៉ៅ នោះទេ ហើយក៏មិនដែលឱ្យលុយទៅឈ្មោះ [redacted] ម៉ៅ ឬប្រើឈ្មោះ [redacted] ម៉ៅ ឱ្យយកថ្នាំញៀនឱ្យទៅគេនោះដែរ ដោយខ្ញុំបាទគ្រាន់តែបានទិញថ្នាំញៀនយកមកជក់ជាមួយនឹងឈ្មោះ [redacted] ម៉ៅ នោះដែរ។ ហើយចំពោះចម្លើយដែលខ្ញុំបាទបានឆ្លើយកន្លងមកខ្ញុំបាទសូមទទួលស្គាល់ថាពិតជាចម្លើយរបស់ខ្ញុំបាទពិតមែន។ ហើយនៅថ្ងៃកើតហេតុវេលាម៉ោងប្រហែលជា ១០ព្រឹកខ្ញុំបាទកំពុងតែសម្រាកនៅក្នុងផ្ទះជួលស្ថិតនៅភូមិព្រៃទា រាជធានីភ្នំពេញ ក៏ស្រាប់តែមានសមត្ថកិច្ចបានចូលមកឃាត់ខ្លួនខ្ញុំបាទតែម្តងដោយមិនដឹងមូលហេតុ ហើយពេលឃាត់ខ្លួននោះ គឺមិនបានដកហូតអ្វីនោះទេ ចំណែកឯថ្នាំញៀនដែលសមត្ថកិច្ចបានដកហូតពីឈ្មោះ [redacted] ម៉ៅ ព្រមទាំងជញ្ជីងនោះ គឺមិនមែនជារបស់ខ្ញុំបាទយកទៅផ្ញើឱ្យឈ្មោះ [redacted] ម៉ៅ នោះទេ ហើយខ្ញុំបាទក៏មិនដែលលក់ ឬឱ្យឈ្មោះ [redacted] ម៉ៅ យកថ្នាំញៀនបន្តឱ្យទៅអ្នកណានោះដែរ។

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ហៅ វ៉ៃ បានឆ្លើយថាៈ ឈ្មោះ [redacted] ណាន បានយកថ្នាំញៀនមកផ្ញើខ្ញុំបាទបាន ០៣លើកមកហើយ និងនៅថ្ងៃកើតហេតុនោះ គឺថ្នាំញៀនដែលសមត្ថកិច្ចបានដកហូតនោះ គឺជារបស់ឈ្មោះ [redacted] ណាន យកមកផ្ញើខ្ញុំបាទ ព្រមទាំងមានជញ្ជីង និងសម្ភារៈវេចខ្ចប់ផងដែរ។

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ណាន បានឆ្លើយថាៈ ខ្ញុំបាទធ្លាប់បានទទួលលុយពីឈ្មោះ [redacted] ម៉ៅ ដើម្បីយកមកទិញគ្រឿងញៀនឱ្យទៅគេបានចំនួនពីរដង ដោយមិនបានយកគ្រឿងញៀនទៅ

ផ្ញើគេ (ឈ្មោះ [redacted] ម៉ៅ) ដូចការលើកឡើងនោះទេ។ ខ្ញុំបាទធ្លាប់លក់ថ្នាំញៀនឱ្យទៅឈ្មោះ [redacted] ម៉ៅ មុនពេលសមត្ថកិច្ចឃាត់ខ្លួននោះប្រហែលជាងកន្លះខែទៅហើយ ប៉ុន្តែនៅមុនថ្ងៃកើតហេតុពីរទៅបីថ្ងៃ និងនៅថ្ងៃកើតហេតុខ្ញុំបាទពុំបានលក់ថ្នាំឱ្យទៅឈ្មោះ [redacted] ម៉ៅ នោះទេ។ ហើយនៅថ្ងៃកើតហេតុនោះ ដដែលពេលសមត្ថកិច្ចឃាត់ខ្លួននោះ គឺមិនបានដកហូតអ្វីពីខ្ញុំបាទនោះទេ។ កន្លងមកក៏មានឈ្មោះ [redacted] ម៉ៅ បានឱ្យលុយមកខ្ញុំបាទដើម្បីទិញថ្នាំញៀនចំនួន ៦០ម៉ឺនរៀលដែរ ដោយខ្ញុំបាទបានយកលុយនោះទៅទិញតែ ៤០ម៉ឺនទៅ ៥០ម៉ឺនរៀលតែប៉ុណ្ណោះ ដោយទុកលុយចាយខ្លះ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ក្រោយពីបានស្តាប់ការដេញដោលសវនាការ ចម្លើយរបស់ជនជាប់ចោទ និងពិនិត្យឯកសារផ្សេងៗដែលមានក្នុងសំណុំរឿងបញ្ជាក់ឱ្យឃើញថា: កាលពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២១ ស្ថិតនៅភូមិត្រពាំងគៀប ឃុំត្រពាំងក្រសាំង ស្រុកបាទី ខេត្តតាកែវ ពិតជាមានអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន។ ដោយឡែកឃើញថា នៅពេលនេះជនជាប់ចោទដែលបានឆ្លើយនៅចំពោះមុខអង្គសវនាការដោយបានឆ្លើយបដិសេធ និងកែប្រែនូវអ្វីដែលបានឆ្លើយកន្លងមក ហើយឃើញថាចម្លើយរបស់ជនជាប់ចោទទាំងពីរនាក់បានឆ្លើយកន្លងមកដោយគ្នាការបង្ខិតបង្ខំនោះទេ ហើយចម្លើយដែលបានឆ្លើយនៅពេលនេះ គឺគ្រាន់តែជាចម្លើយដោះសារតែប៉ុណ្ណោះ។ ដូច្នេះតំណាងអយ្យការស្នើសុំដល់លោកចៅក្រមមិនធ្វើការផ្តល់នូវស្ថានសម្រាលដល់ជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ឡើយ។ ដោយឡែកចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ណាន នៅពេលនេះ គឺបានសហការបានល្អ និងសារភាពទទួលស្គាល់នូវកំហុសផងដែរ។ ហេតុដូច្នេះតំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល និងសូមឱ្យតុលាការសម្រេចផ្តន្ទាទោសលើជនជាប់ចោទទាំងពីរនាក់នេះតាមកំណត់ច្បាប់។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ហៅ វ៉ែ និងឈ្មោះ [redacted] ណាន បានធ្វើសេចក្តីសន្និដ្ឋានការពារឱ្យកូនក្តីថា: ក្រោយពីបានស្តាប់ចម្លើយរបស់កូនក្តីខ្ញុំបាទនៅក្នុងអង្គសវនាការនេះ ឃើញថា: ពីមុនមកឈ្មោះ [redacted] ម៉ៅ បានឆ្លើយលាក់បាំងនូវចម្លើយខ្លះៗ ក៏ប៉ុន្តែនៅក្នុងអង្គសវនាការនេះគាត់បានឆ្លើយសារភាពនូវអ្វីដែលគាត់បានប្រព្រឹត្ត ហើយពាក់ព័ន្ធនឹងចម្លើយរបស់ឈ្មោះ [redacted] ម៉ៅ នេះទៀតសោត គឺគាត់បានឆ្លើយថាគាត់ទិញពីឈ្មោះ [redacted] ណាន ចំណែកឯឈ្មោះ [redacted] ណាន បានឆ្លើយថាថ្នាំញៀននោះ គឺខ្លួនពិតជាបានទិញឱ្យទៅឈ្មោះ [redacted] ម៉ៅ ពិតមែន ប៉ុន្តែលុយដែលទិញនោះជារបស់ឈ្មោះ [redacted] ម៉ៅ។ ដូចនេះឃើញថាចម្លើយនេះ គឺបានឆ្លើយដាក់គ្នាទៅវិញទៅមក ក៏ប៉ុន្តែអង្គហេតុពាក់ព័ន្ធនឹងរឿងនេះ គឺចម្លើយនៅពេលមុនផ្សេង និងចម្លើយនាពេលនេះផ្សេង ប៉ុន្តែបានន័យថាកូនក្តីខ្ញុំបាទតាំងពីរនាក់នេះបានឆ្លើយសារភាពដែរ ប៉ុន្តែពុំសូវចំគោលដៅពេកនោះទេចំពោះអំពើរបស់ខ្លួន។ អញ្ចឹងចម្លើយនៅពេលសវនាការនេះ គឺគាត់បានឆ្លើយរួចហើយនូវអ្វីដែលពួកគាត់បានប្រព្រឹត្តកន្លងមកនោះហើយខ្លួនក៏មិនបានប្រព្រឹត្តអំពើល្មើសអ្វីផ្សេងទៀតដែរ ហើយពាក់ព័ន្ធនឹងការប្រព្រឹត្តនេះទៀតសោត គឺពួកគាត់ធ្លាប់តែបានប្រើប្រាស់នោះទេ តែក៏ចង់បានកម្រៃខ្លះ និងចំណេញតិចតួចក៏ពួកគាត់បានជ្រុលជ្រួសទៅ។ ហេតុដូច្នេះខ្ញុំបាទសំណូមពរសុំដល់ក្រុមប្រឹក្សាជំនុំជម្រះផ្តល់នូវ



Scanned with CamScanner

ស្ថានសម្រាលទោសដល់កូនក្ដីខ្ញុំបាទទាំងពីរនាក់ផង ព្រោះការប្រព្រឹត្តរបស់ពួកគាត់ គឺមិនមែនជាករណីមិនរាងចាលនោះទេ គឺគ្រាន់តែជាការប្រព្រឹត្តលើកទីមួយតែប៉ុណ្ណោះ និងសង្ឃឹមថាតុលាការប្រកាសសាលក្រមលើកូនក្ដីខ្ញុំបាទទាំងពីរនាក់ដោយយុត្តិធម៌។

-សម្ដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ហៅ វ៉ៃ ថា: ខ្ញុំបាទសំណូមពរសុំដល់តុលាការមេត្តាបន្ធូរបន្ថយទោសដល់រូបខ្ញុំបាទផង ព្រោះខ្ញុំបាទបានដឹងពីកំហុសដែលបានប្រព្រឹត្តហើយ និងសូមសន្យាថាពេលចេញពីពន្ធនាគារវិញឈប់ពាក់ព័ន្ធនឹងគ្រឿងញៀននេះទៀតហើយដែរ។

-សម្ដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ណាន ថា: ខ្ញុំបាទសំណូមពរសុំដល់តុលាការមេត្តាបន្ធូរបន្ថយទោសដល់រូបខ្ញុំបាទផង ព្រោះខ្ញុំបាទបានដឹងពីកំហុសដែលបានប្រព្រឹត្តហើយ និងសូមសន្យាថាពេលចេញពីពន្ធនាគារវិញឈប់ប្រើប្រាស់គ្រឿងញៀននេះទៀតហើយដែរ។

-តុលាការប្រកាសបញ្ចប់កិច្ចពិភាក្សាដេញដោលសវនាការនាពេលនេះ និងសម្រេចប្រកាសសាលក្រមនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ០៩ និង ០០នាទីព្រឹក នៅសាលាដំបូងខេត្តតាកែវ។

-ក្រោយពីបាន ស្ដាប់ចម្លើយចម្លើយរបស់ជនជាប់ចោទ។

-ក្រោយពីបាន ពិនិត្យឯកសារ និងភស្តុតាងពាក់ព័ន្ធក្នុងសំណុំរឿង។

-ក្រោយពីបាន ស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ។

-ក្រោយពីបាន ស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ក្រោយពីបាន ស្ដាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ។

-ក្រោយពីបាន ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១-ក្រោយពីធ្វើការស៊ើបសួរតាមនីតិវិធីចប់សព្វគ្រប់ហើយ ចៅក្រមស៊ើបសួរបានចេញដីកាដំណោះស្រាយលេខ: ១៥៦ (ច) /២០២២ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ ដោយបានបញ្ជូនជនត្រូវចោទឈ្មោះ [redacted] ម៉ៅ ហៅ វ៉ៃ ភេទប្រុស អាយុ២៤ឆ្នាំ (កើតឆ្នាំ១៩៩៨) និងឈ្មោះ [redacted] ណាន ភេទប្រុស អាយុ៣២ឆ្នាំ (កើតឆ្នាំ១៩៩០) ជាប់ចោទពីបទ: ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសដែលមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

២-តាមចម្លើយរបស់ជនជាប់ចោទ ព្រមទាំងតាមរបាយការណ៍នានារបស់សមត្ថកិច្ចនៃការិយាល័យប្រឆាំងគ្រឿងញៀននៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តតាកែវ បញ្ជាក់ឱ្យឃើញថា: កាលពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ១៥ និង ៣០នាទី ស្ថិតនៅភូមិត្រពាំងគៀប ឃុំត្រពាំងក្រសាំង ស្រុកបាទី ខេត្តតាកែវ កម្លាំងសមត្ថកិច្ចនៃការិយាល័យប្រឆាំងគ្រឿងញៀននៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តតាកែវ បានចុះបង្ក្រាបករណីជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដោយបានធ្វើការឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ហៅ វ៉ៃ ដោយដកហូតបានថ្នាំញៀនប្រភេទមេតំហ្វេតាមីន

(ICE) ចំនួន ០១កញ្ចប់ធំទម្ងន់ ៤១,៤៨ក្រាម, ជញ្ជីងថ្លឹងថ្នាំញៀនចំនួន ០១គ្រឿង និងសម្ភារៈប្រើប្រាស់ ព្រមទាំងថង់វេចខ្ចប់ថ្នាំញៀនមួយចំនួន ហើយក្រោយមកសមត្ថកិច្ចក៏បានបន្តឃាត់ខ្លួនឈ្មោះ [redacted] ណាន ដែលជាមុខសញ្ញាជួញដូរ និងប្រើប្រាស់ថ្នាំញៀន និងជាអ្នកដែលបានផ្ញើថ្នាំញៀននៅនឹងជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ហៅ វ៉ៃ ពិតមែន។ ក្រោយកើតហេតុសមត្ថកិច្ចបានឃាត់ខ្លួនជនជាប់ចោទទាំងពីរនាក់ខាងលើកសាងសំណុំរឿងបញ្ជូនមកតុលាការដើម្បីចាត់ការតាមនីតិវិធីច្បាប់។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ហៅ វ៉ៃ ដែលបានឆ្លើយបដិសេធថាៈ ថ្នាំញៀនដែលសមត្ថកិច្ចដកហូតនេះ គឺជាថ្នាំញៀនដែលឈ្មោះ [redacted] ណាន បានយកមកផ្ញើទុកនៅនឹងខ្លួនតែប៉ុណ្ណោះ ដោយមិនមែនជាថ្នាំញៀនរបស់ខ្លួននោះទេ ដែលចម្លើយបដិសេធរបស់ជនជាប់ចោទនេះគ្រាន់តែជាការឆ្លើយដោះសារដើម្បីឱ្យខ្លួនរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌតែប៉ុណ្ណោះ និងមិនអាចឱ្យតុលាការជឿជាក់បាននោះទេ ដោយហេតុថាៈ ផ្អែកតាមកំណត់ហេតុចាប់យកវត្ថុតាង និងកំណត់ហេតុទទួលស្គាល់វត្ថុតាងចាប់យកចុះថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២១ ឃើញថាថ្នាំញៀនប្រភេទមេតំហ្វេតាមីន (ICE) ចំនួន ០១កញ្ចប់ធំទម្ងន់ ៤១,៤៨ក្រាម គឺសមត្ថកិច្ចពិតជាបានដកហូតពីជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ហៅ វ៉ៃ ប្រាកដមែន។

៤-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ណាន ដែលបានឆ្លើយបដិសេធថាៈ ខ្លួនមិនដែលលក់ថ្នាំញៀនឱ្យទៅឈ្មោះ [redacted] ម៉ៅ នោះទេ ហើយក៏មិនដែលឱ្យលុយទៅឈ្មោះ [redacted] ម៉ៅ ឬប្រើឈ្មោះ [redacted] ម៉ៅ ឱ្យយកថ្នាំញៀនឱ្យទៅគេនោះដែរ ដែលចម្លើយបដិសេធរបស់ជនជាប់ចោទនេះគ្រាន់តែជាការឆ្លើយដោះសារដើម្បីឱ្យខ្លួនរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌតែប៉ុណ្ណោះ និងមិនអាចឱ្យតុលាការជឿជាក់បាននោះទេ ដោយហេតុថាផ្អែកតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ហៅ វ៉ៃ ដែលបានឆ្លើយថាៈ ចំពោះថ្នាំញៀនប្រភេទមេតំហ្វេតាមីន (ICE) ចំនួន ០១កញ្ចប់ធំទម្ងន់ ៤១,៤៨ ក្រាម គឺជនជាប់ចោទឈ្មោះ [redacted] ណាន បានផ្ញើនៅនឹងរូបខ្លួន (ឈ្មោះ [redacted] ម៉ៅ ហៅ វ៉ៃ ) ដើម្បីទុកយកឱ្យគេបន្ត ហើយសព្វដង (ឈ្មោះ [redacted] ម៉ៅ ហៅ វ៉ៃ) ខ្លួនធ្លាប់ទិញថ្នាំញៀនពីឈ្មោះ [redacted] ណាន ដើម្បីយកមកប្រើប្រាស់ ដោយបានទិញម្តងៗក្នុងតម្លៃ ២០,០០០ (ពីរម៉ឺន) រៀល តែប៉ុណ្ណោះ។ នេះបញ្ជាក់ឱ្យឃើញថាៈ ជនជាប់ចោទឈ្មោះ [redacted] ណាន ពិតជាបានពាក់ព័ន្ធនឹងសកម្មភាពជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនពិតមែន ។

៥-ផ្អែកតាមកំណត់ហេតុធ្វើតេស្តពិសោធន៍រកសារធាតុញៀនក្នុងខ្លួនចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ ឃើញថាៈ ជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ហៅ វ៉ៃ និងឈ្មោះ [redacted] ណាន ពិតជាមានផ្ទុកនូវសារធាតុញៀននៅក្នុងខ្លួនរបស់ពួកគេប្រាកដមែន។

៦-ផ្អែកតាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខៈ ៣៥០៩៩/២២ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបញ្ជាក់ឃើញថាៈ ម្សៅក្រាមសថ្លាចំនួន ០១កញ្ចប់ធំ មានទម្ងន់ ៤១,៤៨ក្រាម (ថ្លឹងទាំងសំបកថង់) របស់ជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ហៅវ៉ៃ និងឈ្មោះ [redacted] ណាន មានវិជ្ជមានសារធាតុញៀនប្រភេទមេតំហ្វេតាមីនដែលមានបរិមាណសារ



Scanned with CamScanner

ជាតុមេតំហ្វេតាមីនគិតជាភាគរយនៃទម្ងន់ ៨០,២៤% នាំឱ្យមានបរិមាណជាតុសុទ្ធស្មើនឹង ៣៣,២៨ ក្រាម ។

៧-យល់ឃើញថាៈ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ណាន ដែលបានធ្វើសកម្មភាពចែកចាយថ្នាំញៀនឱ្យទៅឈ្មោះ [redacted] ម៉ៅ ហៅ វ៉ៃ ហើយឈ្មោះ [redacted] ម៉ៅ ហៅ វ៉ៃ បានយកថ្នាំញៀននោះទៅចែកចាយបន្តឱ្យទៅអ្នកដទៃដើម្បីប្រើប្រាស់បន្តទៀត ព្រមទាំងបាននាំគ្នាប្រើប្រាស់គ្រឿងញៀនផង ដោយចេតនាទុច្ចរិត គឺជាអំពើដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម ជាពិសេសធ្វើឱ្យប៉ះពាល់ដល់សុខភាពខ្លួនឯង និងសុខភាពរបស់អ្នកដទៃទៀតផង ហើយអំពើនោះទៀតសោតត្រូវបានច្បាប់ហាមឃាត់ និងកំណត់ថាជាបទៈ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៨-យល់ឃើញថាៈ ជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ហៅ វ៉ៃ ភេទប្រុស អាយុ២៤ឆ្នាំ (កើតឆ្នាំ១៩៩៨) និងឈ្មោះ [redacted] ណាន ភេទប្រុស អាយុ៣២ឆ្នាំ (កើតឆ្នាំ១៩៩២) គឺជានីតិជនដែលមានស្មារតីយល់ដឹង និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌដែលកើតចេញពីអំពើដែលខ្លួនបានប្រព្រឹត្ត។

៩-យល់ឃើញថាៈ មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ម៉ៅ ហៅ វ៉ៃ ភេទប្រុស អាយុ២៤ឆ្នាំ (កើតឆ្នាំ១៩៩៨) និងឈ្មោះ [redacted] ណាន ភេទប្រុស អាយុ៣២ឆ្នាំ (កើតឆ្នាំ១៩៩២) ពីបទៈ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិត្រពាំងគៀប ឃុំត្រពាំងក្រសាំង ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១០-យល់ឃើញថាៈ ចំពោះថ្នាំញៀនដែលសមត្ថកិច្ចបានដកហូតពីជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ហៅ វ៉ៃ មានចំនួន ០១កញ្ចប់ធំ មានទម្ងន់ ៤១,៤៨ក្រាម (ថ្លឹងទាំងសំបកថង់) មានបរិមាណជាតុសុទ្ធសរុបទម្ងន់ ៣៣,២៨ ក្រាម នាំឱ្យបទល្មើសដែលត្រូវផ្តន្ទាទោសគឺជាបទៈ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និងកថាខណ្ឌទី៥ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១១-តាមការប្តឹងសុំរបស់តំណាងអយ្យការដោយសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ហៅ វ៉ៃ និងឈ្មោះ [redacted] ណាន ពីបទៈ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ តុលាការយល់ឃើញថាៈ ការប្តឹងសុំនេះមានមូលដ្ឋានតាមផ្លូវច្បាប់គ្រប់គ្រាន់ គប្បីសម្រេចតាមការប្តឹងសុំ។

១២-តាមសេចក្តីសន្និដ្ឋានសុំរបស់លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ហៅ វ៉ៃ និងឈ្មោះ [redacted] ណាន ដោយសំណូមពរដល់ក្រុមប្រឹក្សាជំនុំជម្រះផ្តល់នូវស្ថាន

សម្រាលទោសដល់កូនក្តីខ្លួនទាំងពីរនាក់ផង ព្រោះការប្រព្រឹត្តរបស់ពួកគាត់ គឺជាការប្រព្រឹត្តលើកទីមួយតែប៉ុណ្ណោះ ហើយកូនក្តីខ្លួនក៏បានទទួលស្គាល់កំហុសហើយដែរ។ ក្នុងករណីនេះតុលាការយល់ឃើញថា: ការស្នើសុំរបស់លោកមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទនេះមានមូលដ្ឋានតាមផ្លូវច្បាប់គ្រប់គ្រាន់ និងមានហេតុផលសមរម្យ។ ហេតុនេះ គប្បីតុលាការទទួលយកមកពិចារណា។

១៣-យល់ឃើញថា: នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ហៅ វ៉ៃ និងឈ្មោះ [redacted] ណាន មានស្មារតីភ្ញាក់រលឹក និងសន្យាថាឈប់ប្រព្រឹត្តអំពើដែលពាក់ព័ន្ធនឹងគ្រឿងញៀនទៀតហើយដែរ ហើយកម្រិតនៃការអប់របស់ជនជាប់ចោទទាំងពីរនាក់នេះបានតិចតួច ខ្វះការពិចារណាឱ្យបានច្បាស់លាស់ចំពោះអំពើប្រព្រឹត្តរបស់ខ្លួន មួយវិញទៀតឃើញថាបរិមាណធាតុសុទ្ធនៃសារធាតុញៀនដែលសមត្ថកិច្ចបានដកហូតពីជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ហៅ វ៉ៃ គឺមានចំនួន ៣៣,២៨ ក្រាម តែប៉ុណ្ណោះ។ ហេតុដូច្នេះ គប្បីតុលាការសម្រេចពិចារណាក្នុងការផ្តន្ទាទោសដាក់ពន្ធនាគារលើជនជាប់ចោទទាំងពីរនាក់នេះ។

១៤-យល់ឃើញថា: វត្ថុតាងរួមមាន: ក្រាមពណ៌សថ្លាចំនួន០១កញ្ចប់ធំទម្ងន់ ៤១,៤៨ (សែសិបមួយក្បៀសសែសិបប្រាំបី) ក្រាម (ថ្លឹងទាំងសំបកថង់), ជញ្ជីងថ្លឹងថ្នាំញៀនចំនួន ០១គ្រឿង, ខ្សៀសម្រាប់សេពថ្នាំញៀនចំនួន ០៣, ដែកកេះចំនួន ០៣, សម្ភារៈសេព និងថងវេចខ្ចប់ថ្នាំញៀនមួយចំនួន, ទូរស័ព្ទចំនួន ០២គ្រឿងម៉ាកអិនចុចពិល ០១គ្រឿង និងម៉ាក OPPO ០១គ្រឿង និងកាបូបស្ពាយចំនួន ០១ ជាវត្ថុតាងដែលជាប់ពាក់ព័ន្ធនឹងបទល្មើសខាងលើនេះ។ គប្បីតុលាការសម្រេចរឹបអូសតាមបញ្ញត្តិមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពនិត្យគ្រឿងញៀន។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសលើជនជាប់ចោទ:

១.១-ឈ្មោះ [redacted] ម៉ៅ ហៅ វ៉ៃ ភេទប្រុស អាយុ២៤ឆ្នាំ (អត្តសញ្ញាណខាងលើ)

១.២-ឈ្មោះ [redacted] ណាន ភេទប្រុស អាយុ៣២ឆ្នាំ (អត្តសញ្ញាណខាងលើ)

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ចំនួន ០៦ (ប្រាំមួយ) ឆ្នាំ ពីបទ: ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិត្រពាំងគៀប ឃុំត្រពាំងក្រសាំង ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី ០៩ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី ៣ និងកថាខណ្ឌទី៥ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-វត្ថុតាងរួមមាន: ក្រាមពណ៌សថ្លាចំនួន០១កញ្ចប់ធំទម្ងន់ ៤១,៤៨ (សែសិបមួយក្បៀសសែសិបប្រាំបី) ក្រាម (ថ្លឹងទាំងសំបកថង់), ជញ្ជីងថ្លឹងថ្នាំញៀនចំនួន០១គ្រឿង, ខ្សៀសម្រាប់សេពថ្នាំញៀនចំនួន ០៣, ដែកកេះចំនួន ០៣, សម្ភារៈសេព និងថង់វេចខ្ចប់ថ្នាំញៀនមួយចំនួន, ទូរស័ព្ទចំនួន ០២គ្រឿងម៉ាកអិនចុចពិល ០១គ្រឿង និងម៉ាក OPPO ០១គ្រឿង និងកាបូបស្ពាយចំនួន ០១ សម្រេចរឹបអូស។



Scanned with CamScanner

-សាលក្រមនេះបានជំនុំជម្រះជាសាធារណៈនាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២ នៅសាលាដំបូងខេត្តតាកែវ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ហៅ វ៉ៃ និងឈ្មោះ [redacted] ណាន។

-ទុកសិទ្ធិឱ្យប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] |